ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:១០០/២៥.០១.២០១១

សាលដីកា

លេខ: ១៣ ក្រ.III.ស/២៧.៣.២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣

ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ១០០ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ ដែលមាន:

ជនជាប់ចោទឈ្មោះ [redacted] ហឿង ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរៈកម្មករសំណង់ចល័ត កើតនៅ ភូមិមោសឈើ ឃុំគោកខ្ចង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទីលំនៅមុ[redacted] ក្រុម២១ ភូមិទួលរកា២ សង្កាត់ ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ[redacted]មានកូន០២នាក់ ទោសពីមុនគ្មាន,

ឃាត់ខ្លួនថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ឃុំខ្លួនថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០។

មានមេធាវីការពារ លោក[redacted]បុល ។

<u>ត្រូវចោទពីបទ:</u> ប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ផ្ទះលេខ១៨ ភូមិទួលរកា២ សង្កាត់ ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារី ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរៈកម្មករឡេដដ្ឋ បច្ចុប្បន្នរស់នៅ ភូមិក្រពាំងត្របែក ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។

ជនរងគ្រោះឈ្មោះ [redacted] សារីម ភេទស្រី អាយុ១២ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ផ្ទះជួល ផ្លូវលំ ក្រុម២៥ ភូមិទួលរកា២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

## ៦ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោង១៣,០០នាទី ឈ្មោះ [redacted] សារឹម ហៅ ចិន ភេទស្រី អាយុ១២ឆ្នាំ កំពុងអង្គុយលេងនៅមុខផ្ទះជួលលេខ១៨ ភូមិទួលរកា២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលជាផ្ទះរបស់ខ្លួន ស្នាក់នៅជាមួយបងថ្លៃឈ្មោះ [redacted] ហឿង ឆ្លៀតឱកាសបងស្រីមិននៅផ្ទះ ឈ្មោះ [redacted] ហឿង បានហៅជនរងគ្រោះឈ្មោះ [redacted] សារឹម ឲ្យចូលទៅក្នុងបន្ទប់ផ្ទះជួល រួចហើយក៏បានឲ្យ ឈ្មោះ [redacted] សារឹម ដេកលើគ្រែ ប៉ុន្តែឈ្មោះ [redacted] សារឹម មិនព្រម ឈ្មោះ [redacted] ហឿង ក៏បានចាប់បង្ខំរំលោភ រហូតបានសម្រេច ហើយគំរាមមិនឲ្យឈ្មោះ [redacted] សារឹម និយាយរឿងនេះប្រាប់អ្នកណាឲ្យដឹងទេ។ លុះប្រហែលបីបួនថ្ងៃបន្ទាប់មក ឈ្មោះ [redacted] ហឿង កំពុងអង្គុយលេងនៅមុខផ្ទះ ស្រាប់តែឃើញមានសមត្ថកិច្ចទៅដល់ ចាប់ឃាត់ខ្លួនតែម្តង។ កន្លងមកឈ្មោះ [redacted] ហឿង ធ្លាប់បានចាប់រំលោភឈ្មោះ [redacted] សារឹម ជាញឹកញាប់ សរុប មកដល់ពេលនេះមានចំនួន ០៧លើក រួចមកហើយ (ហើយការរំលោភទាំងប៉ុន្មានលើកសុទ្ធសឹងតែបានសម្រេចទាំងអស់) ប៉ុន្តែ មិនចាំថ្ងៃគ្រាន់តែដឹងថា ការចាប់ផ្តើមលើកដំបូងនៅក្នុងខែមិថុនា ឆ្នាំ២០១០។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៥៨ ក្រ១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. កែប្រែបទចោទលើឈ្មោះ [redacted] ហឿង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ផ្ទះលេខ១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ មកជាបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

២. ផ្តន្ទាទោសឈ្មោះ [redacted] ហឿង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ (ដប់ឆ្នាំ) ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ផ្ទះលេខ១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ តាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៣. សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ, មេធាវីការពារជនរងគ្រោះ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ, បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហឿង ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៨ ក្រ១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីអានអានសំបុត្រពេទ្យ ស្តីពីការពិនិត្យការរំលោភផ្លូវភេទលេខ៦១/១០ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ របស់មន្ទីពេទ្យបង្អែករាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] ហឿង ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ សុំឲ្យសាលាឧទ្ធរណ៍បន្ធូបន្ថយទោសឲ្យខ្លួនផង ខ្លួនពិតជាបានប្រព្រឹត្តដូចមានក្នុងអង្គហេតុមែន។ នៅថ្ងៃកើតហេតុ ខ្លួនស្រវឹងស្រា ខ្លួនពិតជាបាន ចាប់ប្អូនថ្លៃឈ្មោះ [redacted] សារីម ហៅ [redacted] ចិន អាយុ១២ឆ្នាំ រំលោភសេពសន្ថវៈ នៅក្នុងផ្ទះ ពេលប្រពន្ធទៅធ្វើការ, ពេលខ្លួនចាប់ឈ្មោះ [redacted] ចិន ប្រកែក ពេលនោះខ្លួនមិនបានដោះសំលៀកបំពាក់នាងទេ ខ្លួនបានប្រព្រឹត្តច្រើនដងតែមិនបានស៊ីជម្រៅទេ គ្រាន់តែញុលៗ ប៉ុណ្ណោះ សរុបចំនួនបីដង។ ខ្លួនសូមសារភាពរឿងដែលខ្លួនបាន ប្រព្រឹត្តទាំងអស់, ក្រោយខ្លួនប្រព្រឹត្តបានបីថ្ងៃ ទើបសមត្ថកិច្ចចាប់ខ្លួន។ សំណូមពរសុំតុលាការបន្ធូរបន្ថយទោស ដល់រូបខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

យល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ តាមមាត្រា៣៨២ នៃក្រមព្រហ្មទណ្ឌ, យល់ឃើញថា ជនជាប់ចោទបានសារភាព ស្របនឹងឯកសារពិនិត្យការ រំលោភផ្លូវភេទលេខ ៦១/១០ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ របស់មន្ទីពេទ្យបង្អែករាជធានីភ្នំពេញ, យោងតាមអង្គហេតុនេះ អាចជាបទ ប្រទូស្តកេរខ្មាស តាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ ចំពោះទណ្ឌកម្ម សុំឲ្យសភាព្រហ្មទណ្ឌពិចារណា អំពីការសារភាពគួរមាន ស្ថានសំរាលដល់ជនជាប់ចោទ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ខ្លួនសុំសន្និដ្ឋានការពារស្របតាមតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។ ក្នុងរឿងនេះ កូនក្តីខ្លួនមិនបានរំលោភសេពសន្ថវៈ តាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋទេ គាត់បានសារភាពថាគាត់បានប្រព្រឹត្ត តែមិនស៊ីជម្រៅទេ គឺចូលក្នុងបទប្រទូស្តកេរខ្មាស តាមមាត្រា២៤៨ ដូចនេះសូមលោកប្រធានមេក្តាប្តូរបទចោទ ពីបទ រំលោភសេពសន្ថវៈ តាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋមកជាបទ ប្រទូស្តកេរ្តិ៍ខ្មាស តាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌវិញ និងសូមក្រុមប្រឹក្សាពិចារណា បន្ធូបន្ថយទោសដល់ កូនក្តីខ្លួន។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍លេខ ៣៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]ហឿង ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ នៅផ្ទះលេខ១៨ ភូមិទួលរកា២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានអំពើចាប់រំលោភលើកុមារីអាយុ១២ឆ្នាំ ម្នាក់បានកើតឡើងដោយមានជនល្មើស ឈ្មោះ [redacted]ហឿង ជាអ្នកប្រព្រឹត្ត។

ករណីនេះ ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានរំលោភសេពសន្ថវៈលើប្អូនថ្លៃខ្លួនឈ្មោះ [redacted]សារឹម ហៅ ចិន ប្រាកដមែន ចំនួនបីដង នៅពេលដែលប្រពន្ធខ្លួនទៅធ្វើការ ឆ្លៀតឱកាសស្ងាត់, ប៉ុន្តែ

មិនបានចូលជ្រៅទៅក្នុងរន្ធទ្វារមាសជនរងគ្រោះទេ ទោះជាខ្លួនបានសម្រេចកិច្ចក៏ដោយ។

៣. តំណាងមហាអយ្យការ បានសន្និដ្ឋានថា ជនជាប់ចោទបានសារភាព ស្របនឹងឯកសារពិនិត្យការរំលោភផ្លូវភេទលេខ ៦១/១០ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ហើយសុំឲ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ សម្រេចកែប្រែបទចោទ និងទណ្ឌកម្ម តាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ។

៤. មេធាវីការពារសិទ្ធិជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារ ស្របតាមតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ និងធ្វើសំណូមពរ ដូចតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

៥. តាមឯកសារពិនិត្យការរំលោភផ្លូវភេទលេខ ៦១/១០ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានពិនិត្យ និងធ្វើសេចក្តីសន្និដ្ឋានថាៈ គ្មានស្លាកស្នាមអ្វីឲ្យកត់សំគាល់នៅលើដងខ្លួន និង អវយវៈ, រន្ធទ្វារមាសធម្មតា, សន្ទះព្រហ្មចារីយ៍ល្អ។

៦. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ ប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅផ្ទះលេខ១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ បទល្មើសមានថែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ។

ដូច្នេះ គួរកែប្រែបទចោទ និងកម្រិតទណ្ឌកម្ម ឲ្យបានត្រឹមត្រូវឡើងវិញ។

៧. សាលក្រមព្រហ្មទណ្ឌលេខ ១៥៨ ក្រ១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែបទចោទ និងកម្រិតទណ្ឌកម្ម គួរកែប្រែដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហឿង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥៨ ក្រ១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូង រាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែបទចោទនៅចំណុចទី១ និងចំណុចទី២ ស្តីពីកម្រិតទណ្ឌកម្ម ត្រូវកែប្រែៈ

ក. កែប្រែបទចោទ ពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ ប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោស តាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ និង

ខ. ផ្តន្ទាទោសឈ្មោះ [redacted] ហឿង ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃឃាត់ខ្លួន ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ពីបទ ប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោស តាមមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ។

ក្រៅពីនេះរក្សាទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ ៦ ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**